**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អគ្គនាយកដ្ឋានពន្ធដារ**
**នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
**លេខ** ១៥០៧ **អពដ**

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០១២

# សេចក្តីជូនដំណឹង
## ស្តីពី
## ការពន្យារពេលបង់ពន្ធលើអចលនទ្រព្យ សម្រាប់ឆ្នាំ២០១២ រហូតដល់ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០១២

អគ្គនាយកដ្ឋានពន្ធដារ មានកិត្តិយសសូមជម្រាបជូនដល់ម្ចាស់អចលនទ្រព្យទាំងអស់នៅរាជធានីភ្នំពេញ និងនៅតាមក្រុងនីមួយៗ នៃខេត្តទាំងអស់ មេត្តាជ្រាបថា ផ្អែកតាមការសម្រេចដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានអនុញ្ញាតឲ្យអគ្គនាយកដ្ឋានពន្ធដារធ្វើការពន្យារពេលជាលើកទី៣លើការប្រមូលពន្ធលើអចលនទ្រព្យសម្រាប់ឆ្នាំ២០១២នេះ រហូតដល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១២ និងអនុញ្ញាតឲ្យលើកលែងពិន័យចំពោះឆ្នាំ២០១១ ដែលមិនទាន់បានបង់ ។ ដូច្នេះ អគ្គនាយកដ្ឋានពន្ធដារសូមជម្រាបជូនម្ចាស់អចលនទ្រព្យទាំងអស់ មេត្តាអញ្ជើញមកបង់ពន្ធអចលនទ្រព្យរបស់ខ្លួនឲ្យបានរស់រាន់មុនថ្ងៃផុតកំណត់ទី៣១ ខែ ធ្នូ ឆ្នាំ ២០១២ ជាកំហិត ។ រាល់អចលនទ្រព្យ ដែលមិនទាន់បានបង់មុនថ្ងៃកំណត់នេះទេ អគ្គនាយកដ្ឋានពន្ធដារ នឹងអនុវត្តនូវការកំណត់ពិន័យតាមច្បាប់ និងចាត់វិធានការរដ្ឋបាលមួយចំនួនដូចជាការឃាត់មិនឲ្យផ្ទេរសិទ្ធិកាន់កាប់ក្នុងការលក់ដូរ ។ល។ ក្នុងនោះដែរ ដើម្បីផ្តល់លទ្ធភាពកាន់តែងាយស្រួលដល់ម្ចាស់អចលនទ្រព្យ អគ្គនាយកដ្ឋានពន្ធដារបានរៀបចំចាត់ចែងផ្តល់សេវាប្រមូលពន្ធនៅថ្ងៃសៅរ៍-អាទិត្យបន្ថែមទៀត ។

អគ្គនាយកដ្ឋានពន្ធដារ មានក្តីសង្ឃឹមយ៉ាងមុតមាំថា នៅក្នុងអំឡុងពេលពន្យារនេះ ម្ចាស់អចលនទ្រព្យទាំងអស់នឹងរួសរាន់មកប្រកាសបង់ពន្ធបានទាន់ពេលវេលាឱ្យចប់សព្វគ្រប់ត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០១២ ខាងមុខនេះជាមិនខាន ។

**ប្រតិភូរាជរដ្ឋាភិបាល**
**ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ**

**គង់ វិបុល**